**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ : ០១៦/២១ សលាន

# សេចក្ដីណែនាំ
## ស្ដីពី
## គោលការណ៍អនុវត្តចំពោះសកម្មភាពការងារ មុខរបរ និងអាជីវកម្ម ពាក់ព័ន្ធផ្នែកអាហារ-ភេសជ្ជៈគ្រប់ប្រភេទ ក្នុង "តំបន់លឿង" នៃភូមិសាស្ត្ររាជធានីភ្នំពេញ

អនុលោមតាមសេចក្ដីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការបន្តការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ **រដ្ឋបាលរាជធានីភ្នំពេញ** បានដាក់ចេញនូវសេចក្ដីសម្រេចលេខ ០៩៧/២១ សសរ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដោយបានកំណត់ភូមិសាស្ត្ររាជធានីភ្នំពេញ ជា **៣ (បី)** **តំបន់** គឺ **"តំបន់ក្រហម"** **"តំបន់លឿងទុំ"** និង **"តំបន់លឿង"** ។

ជាគោលការណ៍ សម្រាប់ **"តំបន់ក្រហម"** រាល់សកម្មភាពការងារ មុខរបរ និងអាជីវកម្មពាក់ព័ន្ធផ្នែកអាហារ-ភេសជ្ជៈគ្រប់ប្រភេទ ត្រូវផ្អាកជាបណ្ដោះអាសន្ន និងសម្រាប់ **"តំបន់លឿងទុំ"** សកម្មភាពការងារ មុខរបរ និងអាជីវកម្មពាក់ព័ន្ធផ្នែកអាហារ-ភេសជ្ជៈគ្រប់ប្រភេទ ត្រូវបានអនុញ្ញាតឱ្យបើកដំណើរការលក់ដូរជាលក្ខណៈវេចខ្ចប់។

យ៉ាងណាមិញ ដោយពិនិត្យឃើញពីភាពចាំបាច់ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងដើម្បីឱ្យសកម្មភាពការងារ មុខរបរ និងអាជីវកម្មពាក់ព័ន្ធផ្នែកអាហារ-ភេសជ្ជៈគ្រប់ប្រភេទ ក្នុង **"តំបន់លឿង"** អាចដំណើរការទៅដោយសុវត្ថិភាព ចៀសវាងការឆ្លងរាលដាលជំងឺកូវីដ-១៩ បន្ថែមទៀត ក្នុងអំឡុងពេលនៃការបិទខ្ទប់ នោះ **រដ្ឋបាលរាជធានីភ្នំពេញ** សូមធ្វើការណែនាំដូចខាងក្រោម៖

១. គ្រប់ទីផ្សារ ភោជនីយដ្ឋាន អាហារដ្ឋាន តូបអាហារ ហាងកាហ្វេ ហាងភេសជ្ជៈ និងអាជីវកម្មដ្ឋានផ្នែកអាហារ-ភេសជ្ជៈគ្រប់ប្រភេទ ក្នុង **"តំបន់លឿង"** **ក៏ត្រូវប្រកបអាជីវកម្មលក់ដូរជាលក្ខណៈវេចខ្ចប់** ដាច់ខាតមិនត្រូវទទួលអតិថិជនឱ្យចូលមកទទួលទានក្នុងបរិវេណអាជីវកម្មដ្ឋានរបស់ខ្លួនឡើយ ដោយត្រូវអនុវត្តរយៈពេល **៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១**។

២. សកម្មភាពការងារ មុខរបរ និងអាជីវកម្មពាក់ព័ន្ធផ្នែកអាហារ-ភេសជ្ជៈគ្រប់ប្រភេទ ដែលបើកដំណើរការនៅក្នុង **"តំបន់លឿង"** ត្រូវអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលឱ្យបានម៉ឺងម៉ាត់ ជាអាទិ៍ ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព និងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការវាស់កម្ដៅ និងការអនុវត្តវិធានការសុវត្ថិភាពផ្សេងទៀត តាមការណែនាំរបស់ក្រសួងសុខាភិបាល។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៥ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

៣.រដ្ឋបាលខណ្ឌទាំង១៤ មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ និងមន្ទីរទេសចរណ៍រាជធានីភ្នំពេញ ត្រូវសហការចុះត្រួតពិនិត្យតាមបណ្ដាគោលដៅទីផ្សារ ភោជនីយដ្ឋាន អាហារដ្ឋាន តូបអាហារ ហាងកាហ្វេ ហាងភេសជ្ជៈ និងអាជីវកម្មដ្ឋានផ្នែកអាហារ-ភេសជ្ជៈគ្រប់ប្រភេទ ក្នុង **"តំបន់លឿង"** ដើម្បីធានាការអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃសេចក្ដីណែនាំនេះ។ ក្នុងករណីរកឃើញថា គណៈគ្រប់គ្រងផ្សារ ឬម្ចាស់អាជីវកម្មដ្ឋានណាមួយ មិនព្រមសហការ ឬ មិនអនុវត្តតាមសេចក្ដីណែនាំនេះ **ត្រូវចាត់វិធានការរដ្ឋបាល និងវិធានការច្បាប់ ដោយគ្មានការលើកលែងឡើយ។**

ទទួលបានសេចក្ដីណែនាំនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខណ្ឌទាំង១៤ ប្រធានមន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ វិស័យឯកជន គណៈគ្រប់គ្រងផ្សារ ម្ចាស់អាជីវកម្មដ្ឋានផ្នែកអាហារ-ភេសជ្ជៈគ្រប់ប្រភេទ អាជីវករ បងប្អូនប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហ ៤ រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២១
**អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន
  *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង១៤
- គ្រប់មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ
  *"ដើម្បីអនុវត្ត"*
- គ្រប់ប្រព័ន្ធឃោសនា
  *"ដើម្បីផ្សព្វផ្សាយ"*
- ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៥ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh